# ការបង្ការអំពើប្រល័យពូជសាសន៍ ៖ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
## វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## របៀបរៀន
## ជា ផល្លា

អ្នករៀនមានបីប្រភេទៈ អ្នករៀនដោយការមើលឃើញនូវអ្វីដែលបានសសេរទុក (ការមើលឃើញ) អ្នករៀន ដោយការស្តាប់នូវអ្វីដែលបានរៀបរាប់ (ការស្តាប់) និងអ្នករៀនតាមរយៈការធ្វើសកម្មភាព (ការធ្វើសកម្មភាព) ។ យើងនឹងប្រើប្រាស់វិធីសាស្ត្រទាំងបីខាងលើ ប៉ុន្តែមនុស្សគ្រប់រូបមានចំណង់ចំណូលចិត្តនៃការរៀនផ្សេងៗពីគ្នា ។ មនុស្សម្នាក់ៗរៀន ហើយនិងទទួលបានព័ត៌មានផ្សេងៗពីគ្នា ។ ស្ថានភាពនៃការរៀនដ៏ល្អបំផុតគឺត្រូវមានការប្រើប្រាស់សំរាប់អ្នករៀនបីប្រភេទខាងលើ ។ គ្រូបង្រៀនដែលបានបញ្ចូលវិធីសាស្ត្រទាំងបីខាងលើ នៅក្នុងមេរៀននឹងទទួលបាននូវប្រសិទ្ធភាពនិងក៏ទទួលបានផងដែរនូវការចូលរួមពីសំណាក់សិស្ស ។

| ចំណេះដឹងជាមូលដ្ឋានគឺត្រូវរៀនតាមរយៈវិញ្ញាណមួយក្នុងចំណោមវិញ្ញាណទាំងប្រាំនេះ | មនុស្សអាចរៀនបានល្អបំផុតពេលដែលបានឮ ឃើញ និងបានធ្វើ ។ ជាទូទៅ មនុស្សចាំល្អបំផុតនៅពេលដែល |
|---|---|
| ការឃើញ = ៨៣ ភាគរយ<br>ការឮ = ១១ ភាគរយ<br>ការប៉ះការ៉ន់ = ៣.៥ ភាគរយ<br>ការហិតក្លិន = ១.៥ ភាគរយ<br>ការភ្លក់រសជាតិ = ១ ភាគរយ | ១០ ភាគរយ នូវអ្វីដែលបានអាន<br>២០ ភាគរយ នូវអ្វីដែលបានឮ<br>៣០ ភាគរយ នូវអ្វីដែលបានឃើញ<br>៥០ ភាគរយ នូវអ្វីដែលបានឮនិងឃើញ<br>៧០ ភាគរយ នូវអ្វីដែលថាតាមពេលនិយាយ<br>៨០-៩០ ភាគរយ នូវអ្វីដែលបានឮ ឃើញ និងធ្វើ |

### ការរៀនតាមរយៈការមើលឃើញ (ខ្ញុំឃើញ)

អ្នករៀនប្រភេទនេះរៀនបានល្អបំផុតតាមរយៈការមើលឃើញ ការប្រើប្រាស់ភ្នែកដែលជាវិធីដ៏ចម្បងក្នុងការរៀន ។ បរិស្ថានដ៏ល្អបំផុតសម្រាប់សិស្សប្រភេទនេះ គឺតម្រូវឲ្យសិស្សឃើញនូវអ្វីដែលបានសរសេរទុក

នៅពេលដែលគ្រូកំពុងតែនិយាយ ការផ្តល់នូវរូបភាពផ្សេងៗដើម្បីបង្ហាញពីអ្វីដែលបានពិភាក្សា និងការមើលឃើញនូវឯកសារដែលបានចែកជូននៅពេលដែលសិស្សកំពុងស្តាប់ការរៀបរាប់របស់គ្រូបង្រៀន ។ រូបភាពគំរូផ្សេងៗ ដែលគ្រូបានបង្ហាញអាចជួយដល់សិស្សប្រភេទនេះរួមមានការប្រើប្រាស់តារាងពេលវេលាដើម្បីបង្ហាញពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ការបង្ហាញតាមរយៈការសរសេរនៅលើក្តារខៀន ការប្រើប្រាស់តារាងនានា ផែនទី ដើម្បីជំនួយដល់ការបង្រៀន ។ រូបថត និងរូបភាពផ្សេងៗអាចជួយដល់សិស្សយល់ពីខ្លឹមសារ និងការបង្រៀនបានប្រសើរជាងការពន្យល់ ។

សិស្សប្រភេទនេះ

- ✓ រីករាយ និងពេញចិត្តនូវសកម្មភាពតាមរយៈការមើលឃើញរូបភាព
- ✓ អន្តេតវត្ថុដែលអាចមើលឃើញគ្រប់យ៉ាងនៅក្នុងថ្នាក់រៀន
- ✓ ពេញចិត្តការមើលឃើញរូបភាពផ្សេងៗដែលកំពុងតែបកស្រាយ
- ✓ មានការពេញចិត្តការមើលឃើញពាក្យដែលបានសរសេរលើក្រដាសឬលើក្តារខៀន
- ✓ មានការពេញចិត្តនូវការណែនាំដែលបានសរសេរមុននឹងធ្វើកិច្ចការផ្សេងៗ
- ✓ មានការពេញចិត្តនូវការមើលឃើញដូចជាតារាងពេលវេលាដើម្បីចងចាំព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ
- ✓ ចងចាំ និងយល់តាមរយៈការបង្ហាញនូវតារាង និងផែនទីជាដើម
- ✓ រៀនតាមរយៈការអាននូវឯកសារ កំណត់ត្រា និងតាមរយៈការរៀបចំគម្រោង
- ✓ រៀបចំដោយយកចិត្តទុកដាក់នូវសម្ភារៈសម្រាប់ការសិក្សា
- ✓ ពេញចិត្តនិងការមើលឃើញរូបភាព និង រូបថត ភ្ជាប់ជាមួយនឹងការរៀបរាប់អំពីរូបភាពទាំងនោះ
- ✓ ពេញចិត្តការបង្ហាញដោយការប្រើប្រាស់ឯកសារសម្រាប់ចែកជូន

រៀនមានប្រសិទ្ធភាពបំផុតតាមរយៈ រូបភាព គំនូរ ផ្ទាំងរូបភាព រូបសំណាក និងសណ្ឋានរូបរាងផ្សេងៗ ។

## ការរៀបរាប់អំពីបែបផែននៃការរៀន

| អ្នករៀនតាមរយៈការមើលឃើញ | ចំណុចគួរយល់ដឹងសម្រាប់អ្នកសិក្សាតាមរយៈការមើលឃើញ |
|---|---|
| - កត់ត្រាទុកយ៉ាងច្រើន<br>- ....<br>- អាចមើលឃើញរូបភាព “សម្លឹងមើល” ទំព័ររបស់សៀវភៅនៅពេលដែលរំលឹកដល់ព័ត៌មាននៅក្នុងនោះ<br>- ត្រូវកត់ត្រាទុកនូវទិសដៅណែនាំ<br>- អាចរំលឹកឃើញមនុស្ស ទីកន្លែង និងឯកសារបានយ៉ាងច្បាស់<br>- មានការលំបាកក្នុងការតាំងអារម្មណ៍នៅពេលដែលមានសំឡេងរំខាន<br>- មានការលំបាកក្នុងការចងចាំរឿងកំប្លែង<br>- ត្រូវសរសេរទុកនូវគំនិតទាំងឡាយបើមិនអីចឹងទេនឹងធ្វើឲ្យមានការភ្លេចភ្លាំង | - ប្រើប្រាស់តារាង ក្រាហ្វិកជាវិធីសម្រាប់សិក្សា<br>- ប្រើប្រាស់បច្ចេកទេសគូរផែនទីឬរៀបចំតាមផែននូវឯកសារផ្សេងៗគ្នា<br>- រកមើលបច្ចេកទេសដែលអាចស្រមើស្រមៃ “រូបរាង” នៃដំណាក់កាលរៀននិងទម្រង់បែបបទផ្សេងៗ<br>- កត់ត្រាយ៉ាងលម្អិតហើយប្រៀបធៀបទៅនឹងអ្នកផ្សេងទៀត<br>- ទុកចន្លោះនៅលើកំណត់ត្រាដូច្នេះអាចបន្ថែមយោបល់ផ្សេងៗទៀតនៅពេលក្រោយ<br>- កត់ចំណាំព័ត៌មានដែលចាំបាច់ដែលនាំឲ្យស្រួលចាំ<br>- ធ្វើការនៅកន្លែងស្ងាត់ (ទោះជាពេលខ្លះតន្ត្រីអាចជួយកំដរពេលធ្វើគណិតវិទ្យាក៏ដោយ)<br>- “គិតទៅលើកិច្ចការ” ។ សរសេរទុកនូវគោលដៅរាល់វគ្គសិក្សានិងជំហាននីមួយៗដើម្បីសម្រេចបានកិច្ចការងារនេះ ។<br>- ត្រូវធ្វើការម្នាក់ឯង<br>- ត្រូវរក្សាទុកខ្មៅដៃនិងក្រដាសនៅក្បែរខ្លួនដើម្បីសរសេរពីគំនិតគោលរបស់ខ្លួន |

## ការរៀនតាមរយៈការស្តាប់ឮ (ខ្ញុំឮ)

អ្នករៀនតាមរយៈការស្តាប់ឮសំឡេងរៀនបានប្រសើរបំផុតតាមរយៈការឮនិងការប្រើប្រាស់ត្រចៀកនិងសំឡេង ជាមធ្យោបាយដ៏សំខាន់ក្នុងការរៀន ។ អ្នករៀនប្រភេទនេះនឹងចងចាំនូវអ្វីដែលបានស្តាប់ឮ និងនូវអ្វីដែលបាននិយាយ ហើយជាទូទៅរៀនមានប្រសិទ្ធភាពបំផុតតាមរយៈការទន្ទេញផ្ទាល់មាត់ ។ អ្នករៀនប្រភេទនេះអាចជាបញ្ហាសម្រាប់គ្រូបង្រៀនដែរ នៅពេលដែលពួកគាត់មានការរំភើបអំពីការរៀនរបស់ពួកគេ ។ អ្នករៀនប្រភេទនេះឆាប់មានការរំខានណាស់តាមរយៈសំឡេងពីខាងក្រៅ ។ ជាមួយគ្នានោះ ពួកគេក៏មានការរំខានផងដែរដោយសារតែនៅក្នុងបរិស្ថានប្រកបដោយភាពស្ងប់ស្ងាត់ពេក ហើយមានការលំបាកតាំងអារម្មណ៍ក្នុងកន្លែងស្ងាត់អស់រយៈពេលជាច្រើនម៉ោង ។

គ្រូបង្រៀនមានធនធានជាច្រើនសម្រាប់អ្នករៀនតាមរយៈការស្តាប់ឮ ។ តាមរយៈធនធានទាំងនោះសិស្សអាចនឹងបញ្ចេញយោបល់ទៅកាន់សិស្សដទៃទៀតដែលជួបប្រទះនូវការលំបាក ។ សិស្សក៏មានការរីករាយ

ហើយយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះមេរៀនដែលគួរឲ្យចាប់អារម្មណ៍ ព្រមទាំងស្តាប់តន្ត្រីផងដែរ ។ វិធីមួយដើម្បីជួយអ្នករៀនតាមរយៈការស្តាប់នេះពេលដែលកំពុងធ្វើតេស្ត ឬក៏ធ្វើសកម្មភាពផ្សេងៗគឺត្រូវមានសំឡេងតន្ត្រីអមជាមួយ ។ វិធីនេះអាចជួយសិស្សផ្តោតទៅលើកិច្ចការ និង រៀនអំពីមេរៀនបានប្រសិទ្ធភាពជាង ។

អ្នករៀនប្រភេទនេះ

✓ រីករាយនិងការបង្រៀនដែលចាប់អារម្មណ៍

✓ រីករាយនិងការពិភាក្សាក្នុងថ្នាក់ និងពិភាក្សាជាមួយអ្នកដទៃ

✓ ចងចាំដោយការនិយាយឮ និងតាមរយៈការទន្ទេញផ្ទាល់មាត់

✓ ចាំនូវអ្វីដែលបានឮ និងការបញ្ចេញយោបល់ផ្ទាល់ខ្លួន

✓ ចូលចិត្តនិយាយតាមរយៈគំនិតយោបល់ដែលមានការលំបាកយល់

✓ អាចចងចាំការណែនាំផ្ទាល់មាត់ដោយមិនចាំបាច់ធ្វើការថតសំឡេង

✓ បញ្ចេញយោបល់ផ្ទាល់មាត់អំពីភាពរំភើបចិត្តទាក់ទងទៅនឹងការរៀនសូត្រ

✓ រីករាយជាមួយសកម្មភាពតន្ត្រីនានា

✓ ងាយស្រួលទទួលនូវការរំខានដោយសំឡេង តែភាពស្ងប់ស្ងាត់ក៏មានការរំខានដងដែរ

✓ មានការលំបាកក្នុងការធ្វើការក្នុងទីកន្លែងស្ងប់ស្ងាត់ក្នុងពេលវេលាយូរពេក

រៀនបានប្រសើរបំផុតតាមរយៈ ការឮ ស្តាប់ភ្លេង វិញ្ញសំឡេង សំឡេង ការសូត្រធម៌ ការណែនាំផ្ទាល់មាត់ និងការស្តាប់ ។

## ការរៀបរាប់អំពីវិធីសាស្ត្រនៃការរៀន

| អ្នករៀនតាមរយៈការស្តាប់ឮ | ចំណុចគួរយល់ដឹងសម្រាប់អ្នកសិក្សាតាមរយៈការស្តាប់ឮ |
|---|---|
| - តែងតែ "ឮ" សំឡេងពាក្យនៅពេលអាន<br>- ទន្ទេញចុះទន្ទេញឡើងនាំឲ្យមានការស្រួលយល់<br>- យល់ឃើញថាការពិភាក្សាយោបល់ម្តងៗជាមួយអ្នកផ្សេងធ្វើឲ្យមានការយល់ដឹងបានច្រើន<br>- ចូលចិត្តបញ្ចប់ការងារមួយឲ្យចប់ស្រេចបាច់សិនមុននិងចាប់ធ្វើការងារផ្សេងទៀត<br>- ចង់បានការប្រាប់ផ្ទាល់មាត់ជាជាងការសរសេរ | - កត់ត្រាទុកនូវគោលបំណងនិងជំហានដើម្បីសម្រេចបានគោលដៅទាំងនោះ<br>- ប្រើប្រាស់ក្រុមសិក្សាឲ្យបានសមរម្យ<br>- ទន្ទេញហើយទន្ទេញទៀតដើម្បីធ្វើឲ្យចាំ<br>- រៀបចំពេលវេលាសិក្សាដូច្នេះអ្នកអាចបំពេញកិច្ចការមួយរួចរាល់មុននឹងចាប់ផ្តើមកិច្ចការមួយផ្សេងទៀត ។ វិធីនេះនាំទៅរកភាពសម្រេចបាន ។ |

| | |
|---|---|
| - ចង់ស្ដាប់សំឡេងជាជាងអានតាមក្រដាស<br>- និយាយឮៗ ពេលកំពុងដោះស្រាយបញ្ហា<br>- ចូលចិត្តការបង្រៀនផ្ទាល់មាត់ជាជាងបង្រៀនតាមឯកសារ | - អានឮៗ នៅពេលដែលកំពុងអានឡើងវិញ ឬនៅពេលហាត់នឿយ<br>- នឹកភ្នកដល់រូបភាពក្នុងចិត្តអំពីអ្វីដែលចង់ធ្វើ<br>- អំឡុងពេលសិក្សា អង្គុយនៅខាងក្រោយគេដើម្បីជៀសវាងនូវការរំខាន |

## អ្នករៀនតាមរយៈការធ្វើសកម្មភាព “ខ្ញុំធ្វើ”

អ្នករៀនតាមរយៈការធ្វើសកម្មភាពរៀនបានល្អបំផុតតាមរយៈការចាប់កាន់និងការប្រើប្រាស់ដៃជាវិធីដ៏ចម្បងក្នុងការរៀន ។ នេះជាវិធីរៀនដ៏សំខាន់ដែលតម្រូវឲ្យមានការកែប្រែមេរៀនដើម្បីឲ្យសមតាមកាលៈទេសៈ ។ អ្នក រៀនប្រភេទនេះរីករាយដោយសារការប្រើប្រាស់រាងកាយដែលពាក់ព័ន្ធទៅនឹងប្រធានបទកំពុងរៀន មិនថាទាក់ទងទៅនឹងការសរសេរប្រកបពាក្យ បង្កើតវត្ថុដើម្បីរៀនគណិតវិទ្យាទេ ។

អ្នករៀនប្រភេទនេះ

- ✓ រីករាយសកម្មភាពរៀនតាមរយៈការប្រើប្រាស់ដៃ
- ✓ រីករាយធ្វើវត្ថុ ឬបំពេញកិច្ចការឲ្យចប់ចុងចប់ដើម
- ✓ ចូលចិត្តប្រើប្រាស់រូបរាងកាយដើម្បីធ្វើសកម្មភាពដែលពាក់ព័ន្ធទៅនឹងប្រធានបទសិក្សា
- ✓ ពេញចិត្តនូវការបង្កើតស្ថានការណ៍តាមរយៈវិធីសាស្ត្រផ្សេងៗ
- ✓ មានការលំបាកក្នុងការអង្គុយមួយកន្លែងយូរក្នុងរយៈពេលដ៏វែងមួយ
- ✓ ចូលចិត្តបង្កើត និងកាន់សម្ភារៈសម្រាប់សិក្សា
- ✓ បង្ហាញនូវភាពរីករាយដោយបញ្ចេញសកម្មភាពរស់រវើកនិងរំភើបចិត្ត
- ✓ ចងចាំនិងយល់តាមរយៈការធ្វើកិច្ចការដោយការធ្វើសកម្មភាព
- ✓ កត់ត្រាទុកនូវហេតុការណ៍នានាដើម្បីធ្វើឲ្យខ្លួនទំនេរ តែមិនបានអានឡើងវិញទេ
- ✓ ចូលចិត្តការប្រើប្រាស់កុំព្យូទ័រ ឬបច្ចេកវិជ្ជាផ្សេងៗ

រៀនបានប្រសើរបំផុតៈ ការធ្វើចលនារាងកាយ ធ្វើកាយវិការ រាំ និងការប៉ះកាន់ គឺសកម្មភាពដែលប្រើប្រាស់រាងកាយ ។

## អ្នករៀបរាប់អំពីវិធីសាស្ត្រនៃការរៀន

| អ្នករៀនតាមរយៈការធ្វើសកម្មភាព | ចំណុចសម្រាប់អ្នកសិក្សាតាមរយៈការធ្វើសកម្មភាព |
|---|---|

| | |
|---|---|
| - ចូលចិត្តធ្វើសកម្មភាពនានាជាជាងអាននិងស្តាប់<br>- ចូលចិត្តកត់ទុកតែមិនបានអានឡើងវិញទេ<br>- អាចខ្វះសណ្តាប់ធ្នាប់ ប៉ុន្តែចាំកន្លែងដែលខ្លួនទុករបស់<br>- មិនចូលចិត្តការធ្វើតេស្ត<br>- ចូលចិត្តការធ្វើគម្រោងនិងកិច្ចការនិងការបង្ហាញផ្សេងៗជាជាងអានរបាយការណ៍ដែលបានសរសេររួច<br>- ប្រើកាយវិការនិងដៃជាច្រើនពេលកំពុងនិយាយ | - រៀនតាមរយៈការប្រើប្រាស់រាងកាយ ដូចជាការដើបឈរ ធ្វើកាយវិការពេលកំពុងទន្ទេញ ឬអាន<br>- ប្រើប្រាស់ពណ៌ដើម្បីកំណត់ចំណាំកន្លែងសំខាន់នៅក្នុងសៀវភៅនិងក្រដាសកត់ត្រា ក្នុងលក្ខណៈរៀបរយល្អ<br>- រកមើលវិធីងាយៗដែលអាចបំពេញការងារបានយ៉ាងលឿនដើម្បីសម្រេចការងារ<br>- រក្សាទុកសៀវភៅសិក្សានៅក្បែរខ្លួន<br>- បំបែកកិច្ចការដែលស្មុគស្មាញឲ្យទៅជាមានភាពងាយស្រួលដែលអាចនាំទៅរកការសម្រេចការងារបាន<br>- អានឮៗនៅពេលកំពុងអាននិងពេលហត់នឿយ<br>- រក្សាទុកបញ្ជីយុទ្ធសាស្ត្រសិក្សាដែលអាចប្រើប្រាស់បាន |

ខាងក្រោមនេះគឺជាតារាងដែលបង្ហាញអំពីការទំនាក់ទំនងគ្នារវាងវិធីនៃការណែនាំ និងសមត្ថភាពនៃការរំលឹកឡើងវិញ ។

| | ការរំលឹកឃើញ៣ម៉ោងក្រោយមក | រំលឹកឃើញ៣ថ្ងៃក្រោយមក |
|---|---|---|
| ការប្រាប់ (ពេលប្រើម្នាក់ឯង) | ៧០ ភាគរយ | ១០ ភាគរយ |
| ការបង្ហាញ (ពេលប្រើម្នាក់ឯង) | ៧២ ភាគរយ | ២០ ភាគរយ |
| ការលាយឡំគ្នារវាងការប្រាប់និងបង្ហាញ | ៨៥ ភាគរយ | ៦៥ ភាគរយ |

ដោយសំអាងទៅលើទំនាក់ទំនងគ្នារវាងវិធីនៃការណែនាំ និងសមត្ថភាពនៃការចងចាំ គ្រូបង្រៀនត្រូវមានគម្រោង ធ្វើសកម្មភាពដែលធ្វើឲ្យសិស្សចូលរួមពាក់ព័ន្ធយ៉ាងសកម្ម ។ សិស្សគួរតែចូលរួមរាល់ដំណាក់កាលនៃកិច្ចប្រជុំនានា ចាប់ពីការធ្វើគម្រោងដល់ការធ្វើការសម្រេចចិត្ត ការអភិវឌ្ឍ និងដល់ដំណាក់កាលវាយតម្លៃផងដែរ ។

កម្រិតនៃការចូលរួមពីសំណាក់សិស្សគឺមានសារសំខាន់ណាស់ក្នុងការឲ្យដឹងថាតើសិស្សបានទទួលចំណេះដឹងបានប៉ុនណាពីការរៀននេះ ។ សកម្មភាពដែលមានលក្ខណៈជាបទពិសោធន៍ជីវិត ហើយការដែលសមាជិកទាំងអស់មានការចូលរួមពាក់ព័ន្ធក្នុងការស្តាប់ឮ និងធ្វើសកម្មភាពគឺជាវិធីរៀនដ៏ប្រសើរបំផុត ។ ជៀសវាងប្រាប់ ឬស្នើសមាជិកនៅក្នុងក្រុមឲ្យអាន ដោយនិយាយថាជាវិធីដ៏ប្រសើរនៃការបង្រៀនឲ្យសោះ ។ បើសិនអាចធ្វើទៅបាន សូមប្រើប្រាស់ការលេងល្បែង ការបង្ហាញ ឬគំរូផ្សេងៗ ។